ព័ត៌មានសង្ខេបអំពីគម្រោង
គ្រប់គ្រងធនធានទឹកចម្រុះ

*សកម្មភាពរួម ដំណោះស្រាយរួម*

# បញ្ហាគ្រប់គ្រងធនធានទឹកក្នុងតំបន់ដីសណ្ដទន្លេមេគង្គ

## កិច្ចសហការរវាងកម្ពុជានិងវៀតណាម






តំបន់ដីសណ្ដទន្លេមេគង្គ លាតសន្ធឹងពីភូមិភាគកណ្ដាលនៃប្រទេសកម្ពុជា រហូតដល់ប្រទេសវៀតណាម ជាទីដែលទន្លេមេគង្គហូរចាក់ទៅសមុទ្រ។ តំបន់នេះត្រូវបានចាត់ទុកជា “ចានបាយរបស់ប្រទេសទាំងពីរ”។ តំបន់ដីសណ្ដនេះមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការធានាសន្តិសុខស្បៀង និងការរកចំណូលរបស់ប្រជាពលរដ្ឋក្នុងប្រទេសទាំងពីរ ប៉ុន្តែការអភិវឌ្ឍន៍វារីអគ្គីសនី នៅតំបន់ខ្សែទឹកខាងលើ និង ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកជំនន់នៅតាមបណ្ដោយតំបន់ដីសណ្ដនេះ បង្កផលប៉ះពាល់ដល់ធនធាននេសាទ តំបន់រងទឹកជំនន់ ចលនាល្បាប់ និង គុណភាពទឹក។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដូចជា គ្រោះទឹកជំនន់និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ និង ការជ្រាបចូលនៃទឹកប្រៃ ក៏បង្កការគម្រាមកំហែងដល់ធនធានធម្មជាតិ នៃតំបន់នេះផងដែរ។

ដើម្បីគ្រប់គ្រងធនធានរួមនៅតំបន់ដីសណ្ដទន្លេមេគង្គនេះ ប្រទេសកម្ពុជា និង ប្រទេសវៀតណាម បានសហការគ្នារៀបចំយន្តការរៀបចំផែនការរួមមួយចំនួន សម្រាប់គ្រប់គ្រងធនធានទឹក តាមរយៈគម្រោងទ្វេភាគី ដែលទទួលបានការគាំទ្រពីគណៈកម្មការទន្លេមេគង្គ (MRC)។

បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់ជាមួយមន្ត្រីរដ្ឋាភិបាល និង តួអង្គពាក់ព័ន្ធនៅមូលដ្ឋាន និងការចុះប្រមូលទិន្នន័យនៅមូលដ្ឋានរួចមក ប្រទេសទាំងពីរ បានកំណត់បញ្ហាធំៗចំនួន ៦ ដើម្បីដោះស្រាយតាមរយៈកិច្ចសហប្រតិបត្តិការនេះ។

## ព័ត៌មានសង្ខេបអំពីគម្រោងតំបន់ដីសណ្ដទន្លេមេគង្គ

គម្រោងគ្រប់គ្រងធនធានទឹកតំបន់ដីសណ្ដទន្លេមេគង្គ គឺជាគំនិតផ្ដួចផ្ដើមមួយ ក្នុងចំណោមគំនិតផ្ដួចផ្ដើមទ្វេភាគីចំនួន ៥ របស់គណៈកម្មការទន្លេមេគង្គ ដើម្បីឆ្លើយតបទៅនឹងបញ្ហាការរៀបចំផែនការ និងគ្រប់គ្រងធនធានទឹកឆ្លងដែន តាមរយៈកិច្ចសហប្រតិបត្តិការ។

ដោយទទួលបាន មូលនិធិពីធនាគារពិភពលោក គម្រោងនេះជម្រុញឲ្យមានការសម្របសម្រួលការអនុវត្តន៍សកម្មភាព ស្របតាមគោលការណ៍នៃការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ដែលជាទស្សនទានសកល មានគោលបំណងធ្វើឲ្យមានតុល្យភាពរវាងតម្រូវការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និង ការគាំពារបរិស្ថានក្នុងសហគមន៍តាមដងទន្លេ។ គម្រោងនេះនឹងបំពាក់បំប៉នប្រទេសទាំង ២ នូវសមត្ថភាព និងឧបករណ៍ ដើម្បីបន្តអនុវត្តសកម្មភាពរួមគ្នា ក្រោយគម្រោងនេះបញ្ចប់។

# បញ្ហាគ្រប់គ្រងធនធានទឹកឆ្លងដែន ជាអាទិភាព៖

ព័ត៌មានលម្អិតអំពីបញ្ហាសំខាន់ៗទាំង ៦ ត្រូវបានកត់ត្រាទុកនៅក្នុងឯកសារបច្ចេកទេសមួយ ដែលមានចំណងជើងថា *បញ្ហានៃការគ្រប់គ្រងធនធានទឹកឆ្លងដែនក្នុងតំបន់ដីសណ្ដទន្លេមេគង្គក្នុងប្រទេសកម្ពុជា និងវៀតណាម* ដែលត្រូវបានបោះពុម្ពផ្សាយក្នុងខែ កញ្ញា ឆ្នាំ ២០១៧។







១

**ការរៀបចំផែនការជាយុទ្ធសាស្ត្រ សម្រាប់ឆ្លើយតបនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត៖** កង្វះការរៀបចំផែនការឆ្លងដែនសម្រាប់គ្រប់គ្រងធនធានតំបន់ដីសណ្ដ ប្រកបដោយនិរន្តរភាព ធ្វើឲ្យប្រទេសទាំងពីរគ្រប់គ្រងគ្រោះទឹកជំនន់ និង គ្រោះរាំងស្ងួត ដែលកើតឡើងជារាងរាល់ឆ្នាំ តែរៀងៗខ្លួន។ នេះគឺដោយសារតែប្រទេសទាំងពីរ មានប្រយោជន៍ជាតិខុសៗគ្នា និង ប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងផ្ដោតលើវិស័យតែមួយ។ ផែនការគ្រប់គ្រងធនធានទឹកឆ្លងដែនជាយុទ្ធសាស្ត្រ អាចជួយបង្កើនការយល់ដឹងអំពីលក្ខខណ្ឌជលសាស្ត្រក្នុងតំបន់នេះ និង ធានាឲ្យមានការសម្របសម្រួលដំណើរការនៅអាងស្តុកទឹកនៅខ្សែទឹកខាងលើ និង ការធ្វើឲ្យមានភាពសុខដុមលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដែលមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងគ្រោះទឹកជំនន់ និង គ្រោះរាំងស្ងួត ដែលកើតឡើងក្នុងប្រទេសទាំងពីរ។

២

**ការអភិវឌ្ឍន៍ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ៖** ការពុំមានយន្តការរៀបចំផែនការ និង ការសហការរួមគ្នារវាងខេត្ត ដែលនៅជាប់ព្រំដែនជាមួយគ្នា ធ្វើឲ្យការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ដីសណ្ដទន្លេមេគង្គនេះ កើតឡើងដោយមិនសមស្រប។ ការអភិវឌ្ឍន៍ប្រព័ន្ធត្រួតពិនិត្យទឹកជំនន់និងប្រព័ន្ធធារាសាស្ត្រដែលពុំមានការសម្របសម្រួលជាមួយគ្នា ដូចជា ការសង់ទំនប់ និងការចាក់ប្រាំងទន្លេ ជាដើម អាចបង្កឲ្យមានគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត នៅតំបន់រងទឹកជំនន់ដទៃទៀត និងអាចនាំឲ្យមានការបំពុលទឹកនិងបញ្ហាខ្វះទឹក និង ធ្វើឲ្យផលិតកម្មកសិកម្មមានការថយចុះ។ ការរៀបចំផែនការសម្របសម្រួលការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ គឺជាការងារដែលចាំបាច់ ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានទាំងនេះ។

៣

**យន្តការសម្របសម្រួល និងទំនាក់ទំនង៖** ប្រទេសកម្ពុជា និងប្រទេសវៀតណាម ខ្វះយន្តការសម្របសម្រួល និង ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងបញ្ហាគ្រប់គ្រងធនធានទឹកឆ្លងដែន ដែលនាំឲ្យមានការធ្វើសកម្មភាពត្រួតគ្នា ការយល់ច្រឡំអំពីស្ថានភាពនៃការប្រើប្រាស់ទឹកនៅតាមតំបន់ព្រំដែនបច្ចុប្បន្ន និង ទំនាស់រវាងវិស័យដែលពាក់ព័ន្ធ។ ប្រទេសទាំងពីរ ចាំបាច់ត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មាន ដែលមានភាពស៊ីគ្នា ដើម្បីប្រមូលដំណើរការ ធ្វើការវិភាគ និង ចែករំលែកទិន្នន័យជលសាស្ត្រឧត្តុនិយម និង ព័ត៌មានពាក់ព័ន្ធដទៃទៀត សម្រាប់ពិនិត្យតាមដានការប្រើប្រាស់ទឹកឆ្លងដែន។

៤

**សមត្ថភាពមនុស្ស និង សមត្ថភាពស្ថាប័ន សម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែន៖** សមត្ថភាពគ្រប់គ្រងធនធានទឹកនៅមានកម្រិត នៅសងខាងបណ្ដោយព្រំដែននៃប្រទេសទាំងពីរ ជាកត្តារួមចំណែកនាំឲ្យការវាយតម្លៃផលប៉ះពាល់ ធ្វើឡើងមិនបានត្រឹមត្រូវ និង ធ្វើឲ្យការអនុវត្តន៍តាមវិធាននីតិវិធី ដែលបានព្រមព្រៀងរួច សម្រាប់ឆ្លើយតបទៅនឹងបញ្ហាការប្រើប្រាស់ទឹកក្នុងទន្លេមេគង្គនៅមានកម្រិតខ្សោយ។ប្រការនេះអាចបន្ទុចបង្អាក់

**ប្រទេស៖**
កម្ពុជា និងវៀតណាម

**ថវិកា៖**
៣៥៤.០០០ ដុល្លារ

**រយៈពេល៖**
ពីខែ ឧសភា ឆ្នាំ ២០១៤ ដល់ ខែ ឧសភា ឆ្នាំ ២០១៨

ដល់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន ដែលបង្កឡើងដោយការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹក។ ចាំបាច់ត្រូវអភិវឌ្ឍសមត្ថភាពស្ថាប័ន និង សមត្ថភាពបច្ចេកទេសបន្ថែមទៀត ដើម្បីឲ្យកិច្ចសហប្រតិបត្តិការ អាចធ្វើទៅបានប្រកបដោយប្រសិទ្ធភាព។



៥ ហេតុប៉ះពាល់បរិស្ថាន សង្គម និងសេដ្ឋកិច្ច ដែលបង្កឡើងដោយការអភិវឌ្ឍន៍ និងការប្រែប្រួលអាកាសធាតុ៖ កង្វះការយល់ដឹងអំពីផលប៉ះពាល់សរុប និង ផលប៉ះពាល់ភ្លាមៗ ដែលបង្កឡើងដោយការអភិវឌ្ឍន៍វារីអគ្គិសនីនៅខ្សែទឹកខាងលើ និងការប្រែប្រួលអាកាសធាតុ អាចនឹងធ្វើឲ្យប្រជាពលរដ្ឋ ដែលរស់នៅតំបន់ដីសណ្តនេះងាយរងគ្រោះដោយសារផលប៉ះពាល់នានា ដូចជា ការកើនឡើងនូវការជ្រាបចូលនៃទឹកប្រៃ ការថយចុះនៃបរិមាណដីល្បាប់និងដីជាតិ ការផ្លាស់ទីរបស់ត្រីមិនញឹកញាប់ដូចមុន និងការផ្លាស់ប្តូររបបលំហូរទឹក។ ចាំបាច់ត្រូវបំពេញភ្លាមនូវកង្វះព័ត៌មានពាក់ព័ន្ធនឹងរបបលំហូរទឹក ម៉ូដែលជលសាស្ត្រ និង ឧបករណ៍ផ្សេងទៀតសម្រាប់វាយតម្លៃផលប៉ះពាល់ ដើម្បីកាត់បន្ថយហេតុប៉ះពាល់ផ្នែកសង្គម-សេដ្ឋកិច្ច និងបរិស្ថាន ដែលកើតឡើងដោយសារការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹក និង ការកើនឡើងកំដៅផែនដី។



៦ ការអនុវត្តន៍កិច្ចព្រមព្រៀងនាវាចរណ៍ទ្វេភាគី៖ ផ្លូវទឹកទន្លេនៃតំបន់ដីសណ្តទន្លេមេគង្គបំពេញតួនាទីយ៉ាងសំខាន់សម្រាប់ការដឹកជញ្ជូនទំនិញ និងសេវានានា ទាំងក្នុងនិងរវាងប្រទេសទាំងពីរ។ ប្រទេសទាំងពីរ បានចុះហត្ថលេខា លើកិច្ចព្រមព្រៀងទ្វេភាគីសម្រាប់ការធ្វើនាវាចរណ៍ទឹកទន្លេ ប៉ុន្តែកិច្ចព្រមព្រៀងនេះមិនត្រូវបានអនុវត្តបានល្អឡើយ ដោយសារហេតុផលជាច្រើន ដូចជា ច្រកសម្រាប់ការធ្វើដំណើររបស់នាវា និងលក្ខខណ្ឌលំហូរទឹក ដែលបង្កឡើងដោយទឹកជំនន់ និងការអភិវឌ្ឍន៍វារីអគ្គិសនី និងចំណុចខ្វះខាតផ្នែកប្រតិបត្តិការនិងរដ្ឋបាលផ្សេងទៀត ដូចជាកង្វះការអនុវត្តន៍គោលនយោបាយបទដ្ឋានសុវត្ថិភាព និងនីតិវិធីអន្តោប្រវេសន៍ ជាដើម។ ប្រទេសទាំងពីរ គួរដោះស្រាយបញ្ហាទាំងនេះ ដើម្បីអាចទទួលបានអត្ថប្រយោជន៍ ពីកិច្ចព្រមព្រៀងទ្វេភាគីនេះ។



## សកម្មភាពទ្វេភាគី ៖

ប្រទេសកម្ពុជា និង ប្រទេសវៀតណាម បានឯកភាពគ្នាចាត់វិធានការជាជំហានៗជាច្រើន ដើម្បីឆ្លើយតបទៅលើបញ្ហាឆ្លងដែនជាអាទិភាព តាមរយៈគម្រោងទ្វេភាគីនេះ៖

១. បង្កើតយន្តការសម្របសម្រួលឆ្លងដែន ដើម្បីកែលម្អការដោះដូរទិន្នន័យនិងព័ត៌មាន និង ការគ្រប់គ្រងធនធានទឹករួមគ្នា

២. រៀបចំផែនការសកម្មភាពរួមគ្នា ដើម្បីអនុវត្តយន្តការសម្របសម្រួលនេះ

បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់ គេរំពឹងថា ប្រទេសទាំងពីរអាចបន្តកិច្ចពិគ្រោះយោបល់ឆ្លងដែនសម្រាប់កិច្ចសហប្រតិបត្តិការគ្រប់គ្រងធនធានទឹក នៅកម្រិតទ្វេភាគីនៅថ្នាក់ខេត្តទៀត។ កិច្ចខិតខំប្រឹងប្រែង ដែលធ្វើឡើងក្នុងរយៈពេលវែងដោយប្រទេសទាំងពីរ អាចនឹងធ្វើឲ្យមានភាពប្រសើរជាងមុនលើការគ្រប់គ្រងគ្រោះទឹកជំនន់ និង គ្រោះរាំងស្ងួត លើកកម្ពស់ការត្រៀមខ្លួនសម្រាប់ទប់ទល់គ្រោះមហន្តរាយ ក៏ដូចជាបង្កើនការធ្វើនាវាចរណ៍ និង ការបង្កើនសកម្មភាពពាណិជ្ជកម្មផងដែរ។


## លេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គ

អាគារលេខ ១៨៤ ផ្លូវ ហ្វាង្ហួម
ប្រអប់សំបុត្រលេខ ៦១០១
ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ

ទូរស័ព្ទ: +៨៥៦ ២១ ២៦៣២៦៣
ទូរសារ: +៨៥៦ ២១ ២៦៣២៦៤
អ៊ីម៉ែល: mrcs@mrcmekong.org
គេហទំព័រ: www.mrcmekong.org

© រក្សាសិទ្ធិគ្រប់យ៉ាងដោយគណៈកម្មការទន្លេមេគង្គ ឆ្នាំ២០១៧